# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១- ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/១១០០/១១

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជាធិបតេយ្យ ឧត្តមសោភណ្ឌោជាតិ ជិតជ្រាបអាណាចក្រ អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៥ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ ជំពូកទី១៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និងពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ប្រកាសអោយប្រើ

ច្បាប់ស្តីពី ច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃ

ទី០៩ ខែសីហា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសំរេចថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែបទប្បញ្ញត្តិ នៃឃ្លាទី១ នៃមាត្រា១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

**ច្បាប់**

**ស្តីពី**

**ច្បាប់បន្ថែមទៅលើច្បាប់ ស្តីពីសវនកម្ម**

**នៃព្រះរាជាណាចក្រកម្ពុជា**

**មាត្រា ១ .-**

ត្រូវបានបំពេញបន្ថែម ជាមាត្រា៥០ ក្នុងជំពូកទី៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខនស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០០០ ដូចតទៅ :

**មាត្រា៥០.-** ក្នុងករណីចាំបាច់ តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា រដ្ឋសភាអាចសំរេចបង្កើតគណៈកម្មការពិសេសដើម្បីពិនិត្យមើលឡើងវិញនូវសកម្មភាព និងកិច្ចប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិ ។

**មាត្រា ២ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

***